00867453

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 07 / 12 / 2012
ម៉ោង (Time/Heure): 16:15
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

E163/5/6

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២

សាធារណៈ / Public

**ជូនចំពោះ:** ភាគីសំណុំរឿង ០០២

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង
មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** សេចក្តីបញ្ជាក់ស្តីពីការដាក់សារណាពាក់ព័ន្ធនឹងច្បាប់ជាធរមាន

១. កាលពីពេលកន្លងទៅនេះ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈចំនួនពីរជូនដល់ភាគីនានាទាក់ទិននឹងការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល។ ជាពិសេស អង្គជំនុំជម្រះស្នើសុំឱ្យភាគីដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលផ្នែកអង្គច្បាប់ជាធរមាន ត្រឹមថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១២ (ឯកសារ E163/5)។ អង្គជំនុំជម្រះក៏បានចេញសេចក្តីណែនាំពាក់ព័ន្ធនឹងខ្លឹមសារ ទម្រង់ និងការកំណត់កាលបរិច្ឆេទនៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ចំពោះផ្នែកដែលនៅសេសសល់ (ឯកសារ E163/5/4)។

២. ក្រុមមេធាវីការពារក្តី នួន ជា បានដាក់សេចក្តីសង្កេតចំពោះសេចក្តីណែនាំរបស់អង្គជំនុំជម្រះស្តីពីការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលនេះ (E163/5/5)។ មេធាវីការពារក្តី នួន ជា បានលើកឡើងនូវការព្រួយបារម្ភមួយចំនួន ប៉ុន្តែការព្រួយបារម្ភទាំងនោះ ត្រូវបានអង្គជំនុំជម្រះដោះស្រាយរួចហើយនៅក្នុងអនុស្សរណៈមុនៗរបស់ខ្លួន។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះ

00867454

E163/5/6

សូមបញ្ជាក់ឱ្យបានច្បាស់លាស់ចំពោះការដាក់ឯកសារដាច់ដោយឡែក ពាក់ព័ន្ធនឹងផ្នែកអង្គច្បាប់ជាធរមាននៃសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ដូចខាងក្រោមនេះ។

៣. អង្គជំនុំជម្រះ មិនតម្រូវឱ្យភាគីដាក់សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលផ្នែកអង្គច្បាប់ដាច់ដោយឡែកពីសេចក្ដីសន្និដ្ឋានស្ថាពរនោះទេ។ អង្គជំនុំជម្រះបានស្នើសុំឱ្យភាគីដាក់សេចក្ដីសន្និដ្ឋានស្ថាពរពាក់ព័ន្ធនឹងច្បាប់ជាធរមាន មិនឱ្យលើសពី ២០ ទំព័រ ត្រឹមថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១២ (E163/5)។ ភាគីអាចមិនធ្វើតាមសំណើសុំនេះបាន។ លើសពីនេះ ភាគីអាចលើកឡើងនូវច្បាប់ជាធរមាននៅក្នុងសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ទោះបីជាភាគី បាន ឬមិនបានលើកឡើងនៅក្នុងសារណាពីមុនក៏ដោយ។ ទោះបីជាបែបនេះក្ដី អង្គជំនុំជម្រះបានបញ្ជាក់អំពីការកំណត់ចំនួនទំព័រសម្រាប់ការដាក់សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល (E163/5/4) ហើយអង្គជំនុំជម្រះនឹងមិនយល់ព្រមឱ្យមានការបង្កើនចំនួនទំព័រតាមការស្នើសុំរបស់ភាគីណាមួយដែលមិនដាក់សារណាដាច់ដោយឡែកពាក់ព័ន្ធនឹងច្បាប់ជាធរមាននោះឡើយ។

៤. បន្ថែមពីលើនេះ អង្គជំនុំជម្រះនឹងសម្រេចលើច្បាប់ជាធរមាននៅក្នុងសាលក្រមរបស់ខ្លួនក្នុងសំណុំរឿង ០០២/០១។ អង្គជំនុំជម្រះនឹងមិនចេញសេចក្ដីសម្រេចដាច់ដោយឡែក ឬសេចក្ដីសម្រេចបឋមពាក់ព័ន្ធនឹងបញ្ហានេះទេ។ អង្គជំនុំជម្រះស្នើសុំឱ្យភាគីដាក់សេចក្ដីសន្និដ្ឋានពាក់ព័ន្ធនឹងច្បាប់ជាធរមានឱ្យបានឆាប់រហ័ស ដើម្បីអាចជួយដល់អង្គជំនុំជម្រះបញ្ចប់ដំណាក់កាលនៃការជំនុំជម្រះ និងដើម្បីអាចឱ្យភាគីអាចលើកឡើងនូវទឡ្ហីករណ៍ដែលពាក់ព័ន្ធនឹងការអនុវត្តច្បាប់ចំពោះអង្គហេតុនានានៅពេលធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ខ្លួន។